អគារ ជីអាយអេ ថៅអឺរ ជាន់ទី៣១ ផ្លូវសុភមង្គល ភូមិ១៤ សង្កាត់
ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

លេខទូរស័ព្ទ៖ (855) 86 999 242

AIA.COM.KH

# អត្ថបទសារព័ត៌មាន

## AIA Cambodia សម្ពោធការិយាល័យកណ្តាលថ្មីដើម្បីបង្ហាញការប្តេជ្ញាចិត្ត

## រយៈពេលយូរអង្វែងកាន់តែមុតមាំដល់ព្រះរាជាណាចក្រកម្ពុជា និងអតិថិជន

**ភ្នំពេញ ថ្ងៃទី 11 ខែមករា ឆ្នាំ 2023** – ក្រុមហ៊ុន អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក (“AIA Cambodia”) បានបើកសម្ពោធការិយាល័យកណ្តាលថ្មីជាផ្លូវការ ជាមួយការប្តេជ្ញាចិត្តរយៈពេលយូរអង្វែងក្នុងនាមជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតឈានមុខគេក្នុងការជួយប្រជាជនកម្ពុជាឱ្យរស់នៅប្រកបដោយសុខភាព និងជីវិតកាន់តែប្រសើរ។

ទីតាំងការិយាល័យកណ្តាលថ្មីនៅអគារ GIA កោះពេជ្រក៏ស្របនឹងគំនិតផ្តួចផ្តើម AIA One Billion របស់ AIA Group ដើម្បីជួយប្រជាជន 1,000,000,000នាក់ នៅអាស៊ីឱ្យមានសុខភាព និងជីវិតកាន់តែប្រសើរនៅឆ្នាំ 2030។ ជាមួយនឹងការសម្ពោធការិយាល័យកណ្តាលថ្មីនេះ AIA Cambodia មានការប្តេជ្ញា "ឆ្ពោះទៅមុខកាន់តែប្រសើរ” ដោយបន្តការអភិវឌ្ឍលើផលិតផល និងសេវាកម្មឱ្យកាន់តែប្រសើរ រួមមាន៖ បន្ថែមសេវាបម្រើអតិថិជនសម្រាប់សហគមន៍ ដៃគូអាជីវកម្ម និងដៃគូពាក់ព័ន្ធ តាមរយៈការផ្តល់ជូនបុគ្គលិក និងទីប្រឹក្សាផែនការជីវិតនូវសម្ភារការិយាល័យទំនើបៗ។

ការិយាល័យកណ្តាលថ្មីរបស់ AIA Cambodia មានបុគ្គលិកជាង 200 នាក់ និងទីប្រឹក្សាផែនការជីវិតជាង 500 នាក់នៅក្នុងអគារស្តង់ដារលំដាប់ A ដែលស្របតាមយុទ្ធសាស្ត្របរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) របស់ AIA Group ដើម្បីជំរុញការផ្លាស់ប្តូរប្រកបដោយអត្ថន័យ និងកសាងគុណតម្លៃឱ្យភាគីពាក់ព័ន្ធក្នុងរយៈពេលមួយយូរអង្វែង។ អគារ GIA Tower ដែលជាអគារស្តង់ដារលំដាប់ A នេះរួមបញ្ចូលការគ្រប់គ្រងអគារកម្រិតខ្ពស់ ដោយបំពាក់នូវបរិក្ខារមុខងារសុខភាព សុវត្ថិភាព និងហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាពខ្ពស់ និងផ្តល់ភាពងាយស្រួល។

ការិយាល័យកណ្តាលពីរជាន់អនុញ្ញាតឱ្យ AIA Cambodia ចូលរួមចំណែកកាន់តែប្រសើរដល់សង្គម ផ្តល់សេវាអតិថិជនកាន់តែប្រសើរ និងធានាឱ្យអតិថិជនទទួលបាននូវការធានារ៉ាប់រងតាមតម្រូវការរបស់ពួកគេក្នុងបរិយាកាសប្រកបដោយសុវត្ថិភាពនៅក្នុងទីតាំងល្អបំផុត។ ការផ្លាស់ប្តូរទីតាំងនេះផ្សារភ្ជាប់នូវគោលបំណងរបស់ខ្លួនក្នុងការបង្កើនការប្រើប្រាស់សេវាធានារ៉ាប់រងនៅក្នុងទីផ្សារកម្ពុជា និងផ្សព្វផ្សាយដល់ប្រជាជនកម្ពុជាកាន់តែទូលំទូលាយអំពីសារៈសំខាន់នៃការការពារផ្នែកហិរញ្ញវត្ថុ និងការសន្សំរយៈពេលវែង។

ការិយាល័យកណ្តាលថ្មីនេះ ក៏មានមជ្ឈមណ្ឌលបណ្តុះបណ្តាល គ្លីនិកពិនិត្យសុខភាពសម្រាប់បុគ្គលិក-អតិថិជន ហាងកាហ្វេ និងសួនច្បារ ដែលត្រូវបានរចនាឡើងដើម្បីផ្តល់ភាពបត់បែន និងស្របតាមចំណង់ចំណូលចិត្តរបស់បុគ្គលិកម្នាក់ៗទាំងពេលធ្វើការ និងការកម្សាន្ត។

ពិធីសម្ពោធការិយាល័យកណ្តាលថ្មីថ្ងៃនេះ ទទួលបានវត្តមានចូលរួមដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម ប៊ូ ច័ន្ទភីរូ អគ្គនាយកនៃនិយតករធានារ៉ាប់រងកម្ពុជា ថ្នាក់ដឹកនាំជាន់ខ្ពស់របស់ AIA Group និង AIA Cambodia ទីប្រឹក្សាផែនការជីវិត បុគ្គលិក ដៃគូពាក់ព័ន្ធ ដៃគូសាជីវកម្មប៊ែងកាសួរេន និងភ្ញៀវកិត្តិយសជាច្រើនរូប។

ក្នុងឱកាសចូលរួមអបអរការិយាល័យថ្មីនេះ ឯកឧត្តម ប៊ូ ច័ន្ទភីរូ មានប្រសាសន៍ថា៖ “ខ្ញុំសូមចូលរួមអបអរសាទរ និងអរគុណដល់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត AIA CAMBODIA ចំពោះសមិទ្ធផលដ៏អស្ចារ្យរបស់ខ្លួនក្នុងរយៈពេល 5 ឆ្នាំចុងក្រោយនេះ។ តាមរយៈពិធីសម្ពោធការិយាល័យកណ្តាលមកទីតាំងថ្មីនេះ AIA Cambodia បានបង្ហាញពីការប្តេជ្ញាចិត្ត និងទំនុកចិត្តយ៉ាងខ្លាំងរបស់ខ្លួនចំពោះវិស័យធានារ៉ាប់រងកម្ពុជា។ ព្រឹត្តិការណ៍ថ្ងៃនេះបានបង្ហាញយ៉ាងច្បាស់ថា AIA CAMBODIA មានចក្ខុ

## អត្ថបទសារព័ត៌មាន

វិស័យច្បាស់លាស់ ឆ្ពោះទៅរកការរីកចម្រើន និងការអភិវឌ្ឍទីផ្សារធានារ៉ាប់រងនៅកម្ពុជា ដែលទីផ្សារនេះមានឱកាសរីកចម្រើនច្រើន បើប្រៀបទៅនឹងទីផ្សារផ្សេងទៀតនៅក្នុងតំបន់”។

លោក Andrew Loh អគ្គនាយកប្រតិបត្តិ AIA Cambodia មានប្រសាសន៍ថា “ការិយាល័យកណ្តាលថ្មីរបស់យើង ប្រៀបទៅនឹងការចាក់គ្រឹះបន្ថែមលើប្រតិបត្តិការ និងការវិនិយោគរយៈពេលយូរអង្វែងនៅកម្ពុជា។ ការិយាល័យកណ្តាលថ្មីនេះ ផ្តល់គុណសម្បត្តិជាច្រើនដើម្បីឈានទៅសម្រេចគោលបំណងរបស់យើងក្នុងការជួយប្រជាជនកម្ពុជាឱ្យរស់នៅមានសុខភាព និងជីវិតកាន់តែប្រសើរ តាមរយៈការខិតខំប្រឹងប្រែងបង្កើនការយល់ដឹងអំពីតួនាទីធានារ៉ាប់រងដែលជាខែលការពារផ្នែកហិរញ្ញវត្ថុពីហេតុការណ៍ចៃដន្យ”។

“ខ្ញុំសូមអរគុណដល់ថ្នាក់ដឹកនាំរបស់ AIA Cambodia ទីប្រឹក្សាផែនការជីវិត និងបុគ្គលិកទាំងអស់ដែលបានជួយសម្រួលដល់ការផ្លាស់ប្តូរទីតាំងមកអគារថ្មីដោយមិនធ្វើឱ្យមានការរាំងស្ទះដល់ប្រតិបត្តិការប្រចាំថ្ងៃរបស់យើង។ យើងគាំទ្រលើទស្សនៈ “ប្រសើរ” ដែលជំរុញឱ្យយើងបន្តអភិវឌ្ឍរាល់កិច្ចការរបស់យើងឱ្យកាន់តែប្រសើរពីមួយកម្រិតទៅមួយកម្រិតទៀត។ អ្នកគ្រប់គ្នាបានប្រកាន់ខ្ជាប់នូវផ្នត់គំនិតនេះ ដើម្បីធ្វើឱ្យការិយាល័យថ្មីរបស់យើងមាន ភាពកក់ក្តៅ និងជាកន្លែងមួយប្រកបដោយផាសុកភាព ក្នុងការបម្រើអតិថិជនឱ្យបានប្រសើរជាងមុន និងបំពេញតម្រូវការការសន្សំ និងការការពារហិរញ្ញវត្ថុរបស់ពួកគេ”។

ដើម្បីដឹងច្បាស់អំពីការិយាល័យកណ្តាលថ្មីរបស់ AIA Cambodia និងសម្រាប់ព័ត៌មានលម្អិតលើដំណោះស្រាយការការពារជំងឺធ្ងន់ធ្ងរ គ្រោះថ្នាក់ចៃដន្យ ដំណោះស្រាយការពារគ្រួសារអ្នក និងអ្នក សូមផ្ញើអ៊ីមែលមកកាន់ kh.marketing@aia.com ឬចូលទៅកាន់គេហទំព័រ aia.com.kh និង www.facebook.com/AIACambodia។

### អំពី AIA Cambodia

*ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត AIA Cambodia គឺជាបុត្រសម្ព័ន្ធនៃ AIA Group មានក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតនៅទូទាំងតំបន់អាស៊ីដែលស្ថិតក្នុងបញ្ជីឈ្មោះសាធារណៈឯករាជ្យធំជាងគេ។ ក្រុមហ៊ុនមានវត្តមាននៅលើទីផ្សារចំនួន 18 ប្រទេសនៅអាស៊ីប៉ាស៊ីហ្វិក - សាខាគ្រប់គ្រងទាំងស្រុង។*

*ចាប់តាំងពីបើកដំណើរការនៅកម្ពុជា រាល់សកម្មភាពរបស់ AIA Cambodia ធ្វើឡើងស្របតាមគោលបំណង ក្នុងការជួយឱ្យប្រជាជនកម្ពុជាឱ្យរស់នៅមានសុខភាព និងជីវិតកាន់តែប្រសើរ។ ចាប់តាំងពីចាប់ផ្តើមអាជីវកម្មក្នុងឆ្នាំ 2017 យើងបានក្លាយជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតដំបូងបង្អស់នៅកម្ពុជា ផ្តល់ការការពាររហូតដល់ 26 ស្ថានភាពជំងឺធ្ងន់ធ្ងរ។*

*ក្នុងនាមជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតឈានមុខគេមួយនៅកម្ពុជា AIA Cambodia ផ្តល់ជូននូវដំណោះស្រាយជីវិតឈានមុខគេនៅលើទីផ្សារសម្រាប់ប្រជាជនកម្ពុជាគ្រប់មជ្ឈដ្ឋាន រាប់ចាប់ពីគម្រោងធានារ៉ាប់រងសំខាន់ៗដែលបង្កើតឡើងស្របតាមតម្រូវការជាក់លាក់ ដែលរួមមានគម្រោងការពារលើជំងឺធ្ងន់ធ្ងរ គ្រោះថ្នាក់ចៃដន្យ ថ្លៃសម្រួលការសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងជំនួយសង្គ្រោះបន្ទាន់នៅក្រៅប្រទេស។*

*AIA Cambodia ផ្តោតសំខាន់លើការណែនាំ និងជម្រុញឱ្យប្រជាជនក្នុងសង្គមទទួលយកទម្លាប់ល្អៗ ក៏ដូចជាមធ្យោបាយដើម្បីឱ្យពួកគាត់ទទួលបាននូវសុខភាពល្អ តាមរយៈគំនិតផ្តួចផ្តើម រួមមានកិច្ចសហការ ជាមួយក្រសួងកិច្ចការនារី ដើម្បីពង្រឹងលើសមភាពយេនឌ័រនិងសិទ្ធិស្ត្រី ការលើកកម្ពស់ការយល់ដឹងអំពីជំងឺមហារីកសុដន់ តាមរយៈយុទ្ធនាការប្រចាំឆ្នាំ Fit for Hope របស់យើងជាដើម។*

អគារ ជីអាយអេ ថៅអឺរ ជាន់ទី៣១ ផ្លូវសុភមង្គល ភូមិ១៤ សង្កាត់
ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

លេខទូរស័ព្ទ៖ (855) 86 999 242

AIA.COM.KH

# អត្ថបទសារព័ត៌មាន

*យើងខ្ញុំក៏ចូលរួមជួយលើកស្ទួយកុមារដែលជួបបញ្ហាជីវភាពរាប់ពាន់នាក់ផងដែរ ដោយតាមរយៈឧបត្ថម្ភដល់លីគបាល់ទាត់ AIA-ISF ដែលជាលីគបាល់ទាត់ថ្នាក់មូលដ្ឋានធំជាងគេនៅកម្ពុជា។*

*ជាងនេះទៀតសោធ យើងក៏សហការជាមួយក្លឹបTottenham Hotspur ក្នុងក្របខណ្ឌ English Premier League ដែលជាដៃគូសកល និងជាក្លឹបបាល់ទាត់កំពូលនៅលើពិភពលោក ដើម្បីធានាថាកុមារទាំងនោះទទួលបានការអប់រំដែលពួកគេសមនឹងទទួលបាន។*

*AIA Cambodia គឺជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតកម្ពុជាតែមួយគត់ដែលបានទទួលពានរង្វាន់*

*"ក្រុមហ៊ុនល្អបំផុតសម្រាប់ការងារនៅអាស៊ី (Best Companies to Work for in Asia)" ពី HR Asia ក្នុងរយៈពេល 3ឆ្នាំជាប់គ្នា 2020, 2021 និង 2022។*

*AIA Cambodia មានការិយាល័យកណ្ដាលនៅទីក្រុងភ្នំពេញ និងបច្ចុប្បន្នបានពង្រីកសាខានៅខេត្តសៀមរាប កំពត កំពង់ចាម និងបាត់ដំបង។*

*ព័ត៌មានបន្ថែមតាមរយៈគេហទំព័រ www.aia.com.kh*